# គោលការណ៍ស្តីពីការប្រាប់យើងខ្ញុំ (TELL US)

**កំណែទីមួយ (មករា 2024)**

## ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន Primark

នៅក្រុមហ៊ុន Primark យើងមានគោលបំណងធ្វើពាណិជ្ជកម្មតាមរបៀបត្រឹមត្រូវ។ យើងមានការប្តេជ្ញាចិត្តចំពោះការប្រព្រឹត្តសុចរិត ជានិច្ច។ យើងមានមោទនភាពក្នុងការលើកកម្ពស់និងមានគោលបំណងការពារវប្បធម៌នៃ ភាពបើកចំហ ភាពស្មោះត្រង់ និងការរួមបញ្ចូល ដែលនាំមកនូវការអនុវត្តប្រកបដោយការទទួលខុសត្រូវជាចម្បង។

យើងប្តេជ្ញាចិត្តចំពោះការលើកកម្ពស់កន្លែងធ្វើការដែលមានសុវត្ថិភាព និងមានភាពសមរម្យឲ្យដល់កម្មករកម្មការិនី នៅក្នុងសង្វាក់ផ្គត់ផ្គង់របស់យើង។ យើងដឹងថា យើងគឺជាក្រុមហ៊ុនដ៏រឹងមាំមួយ នៅពេលដែលកម្មករកម្មការិនី ក្រុមអ្នកផ្គត់ផ្គង់ និងមនុស្សដែលរស់នៅក្បែរៗរោងចក្រដែលផ្គត់ផ្គង់ផលិតផលរបស់ក្រុមហ៊ុន Primark មានអារម្មណ៍ទទួលបានការផ្តល់សិទ្ធិនិយាយចេញមក និងប្រាប់យើង អំពីការប្រព្រឹត្តមិនត្រឹមត្រូវ មិនស្មោះត្រង់ មិនស្របច្បាប់ ឬ អាកប្បកិរិយាគ្រោះថ្នាក់ ដែលពួកគាត់បានជួបប្រទះ។ យើងលើកទឹកចិត្តឲ្យមានការប្រាស្រ័យទាក់ទងគ្នាប្រកបដោយប្រសិទ្ធភាព និងភាពស្មោះត្រង់នៅគ្រប់កម្រិតនៃសង្វាក់ផ្គត់ផ្គង់ និងសហគមន៍របស់យើង។ គោលការណ៍ស្តីពីការប្រាប់យើងខ្ញុំ(Tell Us) មានការកែប្រែតម្រង់តាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តី អំពីធុរកិច្ច និងសិទ្ធិមនុស្ស (UNGPs) និងដំណើរការជាជំហានៗលក្ខខណ្ឌបញ្ញត្តិច្បាប់ដែលជាតម្រូវការពាក់ព័ន្ធដែលយើងបានដឹង។

## តើហេតុអ្វីបានជាអ្នកត្រូវប្រាប់យើង?

ក្នុងករណីដែលអ្នកជាកម្មករ/កម្មការិនី ឬជាអ្នកផ្គត់ផ្គង់ក្នុងសង្វាក់ផលិតកម្មយើងខ្ញុំ ឬអ្នករស់នៅក្បែរៗរោងចក្រដែលធ្វើការផ្គត់ផ្គង់ផលិតផលឱ្យក្រុមហ៊ុន Primark ហើយ អ្នកចាប់ផ្តើមអង្កេតឃើញរឿងអ្វីមួយដែលអ្នកជឿជាក់ថា មិនត្រឹមត្រូវ មិនស្មោះត្រង់ មិនស្របច្បាប់ ឬមានគ្រោះថ្នាក់នោះ យើងចង់ឲ្យអ្នកចេញមក និង បង្ហាញអំពីកង្វល់របស់អ្នក។ យើងមានប្រព័ន្ធការសម្ងាត់ និងអនាមិក(លុះត្រាតែយើងត្រូវតែបង្ហាញដោយហេតុផលផ្លូវច្បាប់) ប្រាប់យើងខ្ញុំ(Tell us) ដែលនឹងអនុញ្ញាតឲ្យអ្នកធ្វើយ៉ាងដូច្នោះបាន។ វាគ្របដណ្តប់តាមរយៈគោលការណ៍ស្តីពីប្រាប់យើងខ្ញុំ(Tell us) នេះ។ តាមរយៈការនិយាយចេញមក វិធានការអាចត្រូវបានធ្វើឡើងដើម្បីស៊ើបអង្កេត និងដោះស្រាយបញ្ហា។

សូមមេត្តាជ្រាបថា ប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ(Tell us) មិនមែនជំនួសឲ្យគោលការណ៍ និងនីតិវិធីស្តីនៅកន្លែងធ្វើការធម្មតារបស់អ្នក (ដូចជា បណ្តឹងសាទុក្ខ និងយន្តការដាក់វិន័យ ឬសហជីព គណៈកម្មាធិការកម្មករឬនិយោជិតណាមួយ ដែលអាចមានសម្រាប់អ្នក ។

## តើអ្នកណាអាចប្រើប្រាស់ប្រព័ន្ធប្រាប់យើងខ្ញុំ(Tell Us) បាន?

យើងសូមលើកទឹកចិត្តឲ្យកម្មករកម្មការិនី និងក្រុមអ្នកផ្គត់ផ្គង់នៃក្រុមហ៊ុន Primark និងប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្បែរៗរោងចក្រផ្គត់ផ្គង់ផលិតផលនៃក្រុមហ៊ុន Primark និយាយឡើង និង ប្រាប់មកយើងខ្ញុំ។ កម្មករកម្មការិនីគ្រប់ប្រភេទដែលមានជាអាទិ៍ ដូចជា អ្នកធ្វើការពេញម៉ោង ក្រៅម៉ោង ឬរយៈពេលកំណត់ កម្មករស៊ីឈ្នួលធ្វើការម្តងម្កាល ឬតាមរយៈទីភ្នាក់ងាររកការងារឲ្យធ្វើ អ្នកធ្វើការតាមផ្ទះ អ្នកធ្វើការតាមតួនាទី/កន្លែងផ្សេងៗ សិក្ខាកាម ឬក្រុមអ្នកស្ម័គ្រចិត្ត។

សហការី/សហការិនីដែលកំពុងធ្វើការដោយផ្ទាល់ឲ្យក្រុមហ៊ុន Primark នៅតាមប្រទេសទាំងឡាយណាដែលយើងខ្ញុំមានហាង និងម្ចាស់ភាគហ៊ុន Primark, ភ្នាក់ងារ, អ្នកម៉ៅការ, ទីប្រឹក្សាពីខាងក្រៅ, អ្នកតំណាងភាគីទីបី, ដៃគូពាណិជ្ជកម្ម ឬម្ចាស់ឧបត្ថម្ភកម្មវិធីនានា ទទួលបានការលើកទឹកចិត្តឲ្យប្រើយន្តការនិយាយប្រាប់របស់ក្រុមហ៊ុន Primark។ អ្នកអាចស្វែងយល់បានច្រើនទៀតនៅត្រង់នេះ: https://corporate.primark.com/en-gb/primark-cares/resources/social។

## តើអ្នកត្រូវប្រាប់យើងអំពីអ្វីខ្លះ?

បើអ្នកជឿជាក់ថា មានការប្រព្រឹត្តមិនត្រឹមត្រូវ មិនស្មោះត្រង់ មិនស្របច្បាប់ ឬមានអាកប្បកិរិយាគ្រោះថ្នាក់កំពុងកើតមានឡើង អ្នកអាចលើក ក្តីកង្វល់ជាមួយហ្នឹងទំនុកចិត្តដែលយើងខ្ញុំនឹងគាំទ្រលោកអ្នក។ អ្នកត្រូវរាយការណ៍ណាមួយដូចខាងក្រោម:

- ការរំលោភបំពានលើ ក្រមសីលធម៌ស្តីពីអ្នកផ្គត់ផ្គង់ របស់ក្រុមហ៊ុន Primark ដែលមានជាអាទិ៍:
    - ពលកម្មដោយបង្ខំ ឬការបញ្ជាក់ភស្តុតាងណាមួយផ្សេងទៀតនៃបញ្ហាទាសភាពនាសម័យទំនើប
    - ការមិនបើកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ដែលគេត្រូវទទួលបានស្របច្បាប់
    - ការទប់ស្កាត់ ឬការបង្អាក់ចំពោះការចូលរួម ឬការបង្កើតសហជីព ឬការចចារជារួម
    - បរិយាកាសកន្លែងធ្វើការងារគ្មានសុវត្ថិភាព ឬគ្មានអនាម័យ
    - បញ្ហាម៉ោងធ្វើការលើសពីកម្រិតអតិបរិមាដែលច្បាប់កំណត់
    - ការរើសអើង ការសម្លុតគំរាមកំហែង ឬការបៀតបៀន

  - អាកប្បកិរិយាបំពាន ឬបង្ខិតបង្ខំ
  - ការខូចខាតបរិស្ថាន និង
  - ការស៊ីសំណូក និងអំពើពុករលួយ។
- ការបំពានគោលការណ៍ក្រុមហ៊ុន Primark ណាមួយផ្សេងទៀតដែលទាក់ទងនឹង បញ្ហាសិទ្ធិមនុស្ស និងសីលធម៌ និង បញ្ហាដល់បរិស្ថាន
- ការលាតត្រដាងព័ត៌មានសម្ងាត់ ឬការរំលោភបំពានប្រើប្រាស់ទិន្នន័យផ្សេងទៀតដោយគ្មានការអនុញ្ញាតត្រឹមត្រូវ
- ការចុះកិច្ចសន្យាបន្តលើការបញ្ជាទិញរបស់ក្រុមហ៊ុន Primark ដោយគ្មានការអនុញ្ញាតត្រឹមត្រូវ
- សកម្មភាពបោកបន្លំលុយកាក់ និង
- ការលាក់បាំងដោយចេតនានៃណាមួយខាងលើ។

បញ្ហាអ្វីមួយដែលមិនមានការបញ្ចូលក្នុងបញ្ជីខាងលើ អាចរបាយការណ៍តាមរយៈប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ(Tell Us) ដោយប្រើជម្រើសទី 4 (ដែលមានចែងខាងក្រោម)។

ក្នុងករណីដែលអ្នកមិនច្បាស់ថាតើបញ្ហានោះមួយស្ថិតនៅក្នុងវិសាលភាពនៃគោលការណ៍ប្រាប់យើងខ្ញុំនេះ ឬក្នុងករណីដែលអ្នកចង់និយាយទៅកាន់នរណាម្នាក់ដែលមានទំនុកចិត្តមុននឹង ធ្វើរបាយការណ៍ផ្លូវការ យើងសូមណែនាំឲ្យអ្នកនិយាយទៅកាន់អ្នកគ្រប់គ្រង ឬប្រធានរបស់អ្នក ឬ (បើមាន) សហជីព ឬ តំណាងគណៈកម្មាធិការកម្មករនិយោជិតនៅកន្លែងអ្នក ឬកន្លែងធ្វើការរបស់អ្នក។

## តើអ្នកលើកយកបញ្ហាទៅ តាមរយៈប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ(Tell Us) យ៉ាងដូចម្តេច?

សូមមេត្តាមើលបណ្តាជម្រើសខាងក្រោម ដើម្បីលើកយកបញ្ហាកង្វល់ណាមួយ។ **បើអ្នក ឬអ្នកផ្សេងទៀតកំពុងស្ថិតក្នុងគ្រោះថ្នាក់បន្ទាន់សូមទាក់ទងទៅផ្នែកសង្គ្រោះបន្ទាន់នៅមូលដ្ឋានរបស់អ្នក។**

### *ជម្រើសទី 1: ប្រាប់ទៅអ្នកគ្រប់គ្រង/ប្រធានរបស់អ្នក*

យើងសូមស្នើ ឬណែនាំឲ្យអ្នកលើកឡើងពីបញ្ហាកង្វល់របស់អ្នកប្រាប់ទៅអ្នកគ្រប់គ្រង ឬប្រធានរបស់អ្នកដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ ក្នុងករណីដែលអ្នកមានបញ្ហាកង្វល់អំពីការទាក់ទងអ្នកគ្រប់គ្រង ឬប្រធានរបស់អ្នកដោយសារតែបញ្ហាអាក្បបកិរិយាដែលអ្នកបានសង្កេតឃើញនោះ យើងសូមលើកទឹកចិត្តឲ្យអ្នកប្រើបណ្តាជម្រើសដែលមានចែងខាងក្រោម។

### *ជម្រើសទី 2: ក្នុងករណីដែលមាននិងអាចធ្វើទៅបាន ចូរទាក់ទងសហជីព ឬតំណាងកម្មករនិយោជិតនៅមូលដ្ឋានរបស់អ្នក*

បើអ្នកមានអារម្មណ៍ថាមិនអាចលើកបញ្ហាទៅប្រាប់អ្នកគ្រប់គ្រង ឬប្រធានរបស់អ្នកបាន ឬបើអ្នកមានអារម្មណ៍ថាអ្នកគ្រប់គ្រង ឬប្រធានរបស់អ្នកមិនបានដោះស្រាយកង្វល់របស់អ្នកទេ (ក្នុងករណីដែលមាននិងអាចធ្វើទៅបាន) អ្នកអាចនាំយកបញ្ហានេះទៅពិភាក្សាជាមួយសហជីព ឬតំណាងកម្មករនិយោជិតនៅមូលដ្ឋានរបស់អ្នកបាន។

### *ជម្រើសទី 3: ក្នុងករណីដែលមាននិងអាចធ្វើទៅបាន សូមទាក់ទងតាមប្រព័ន្ធទូរសព្ទសុំជំនួយរបស់កម្មករនិយោជិតនៅមូលដ្ឋានអ្នក (សូមមើលឧបសម្ព័ន្ធទី 1)*

ក្នុងករណីដែលអ្នកមិនអាចលើកយកបញ្ហាប្រាប់ទៅអ្នកគ្រប់គ្រង ឬប្រធាន ឬតំណាងសហជីព ឬតំណាងកម្មករនិយោជិតរបស់ អ្នកបាន ឬ បើមិនដូច្នោះទេ អ្នកបានធ្វើវាហើយ ហើយអ្នកមានអារម្មណ៍គិតឃើញថាបញ្ហាកង្វល់របស់អ្នកមិនទាន់ទទួលបានការដោះស្រាយទេ (ក្នុងករណីដែលអាចនិងធ្វើទៅបាន) អ្នកអាចនាំយកបញ្ហានោះទៅរាយការណ៍តាមប្រព័ន្ធទូរសព្ទស្នើសុំជំនួយ
របស់កម្មករនិយោជិតនៅមូលដ្ឋានដែលបានប្រាប់ខាងក្រោមនៅ ឧបសម្ព័ន្ធទី 1។

### *ជម្រើសទី 4: បណ្តាញទូរសព្ទប្រាប់យើងខ្ញុំ (ព័ត៌មានពិស្តារខាងក្រោម និងក្តារខៀនប្រកាសព័ត៌មាននៅតាមរោងចក្រដែលធ្វើផលិតផលក្រុមហ៊ុន Primark)*

ក្នុងករណីដែលអ្នកមិនអាចប្រើជម្រើសទី 1, 2 និង 3 បាន
ឬក្នុងករណីដែលបញ្ហាកង្វល់របស់អ្នកមិនទាន់មានការលើកយកមកដោះស្រាយតាមរយៈជម្រើសផ្សេងៗទៀតទេនោះ
សូមប្រើបណ្តាញទូរសព្ទ ប្រាប់យើងខ្ញុំ សេវាលើវិបសាយ ឬកម្មវិធីស្មាតហ្វូនដែលមិនគិតថ្លៃទាំងអស់ ដោយប្រើព័ត៌មានលម្អិតខាងក្រោម។

| **ទូរសព្ទ** | **អាសយដ្ឋានវិបសាយ** | **កូដចូលប្រើ** | **កូដ QR** |
|---|---|---|---|
| កម្ពុជា៖ 1800209867 | https://primark.speakup.report/tellus | 106502 | |

| | | | |
|---|---|---|---|

ក្នុងករណីដែលអ្នកសម្រេចហៅតាមបណ្ដាញទូរសព្ទប្រាប់យើងខ្ញុំ អ្នកនឹងស្ដាប់ឮសារដែលបានថតទុក (ក្នុងករណីភាគច្រើនជាភាសាក្នុងស្រុករបស់អ្នក) ដែលស្នើសុំឲ្យអ្នកផ្ដល់លេខកូដ តែមួយគត់ចំពោះក្រុមហ៊ុន Primark (106502)។ នៅពេលនោះ អ្នកអាចនឹងថតសារជាសំឡេង ដែលអ្នកត្រូវបកស្រាយលម្អិតអំពីបញ្ហាកង្វល់របស់អ្នក។

ក្នុងករណីដែលអ្នកសម្រេចប្រើប្រាស់សេវាលើវិបសាយប្រាប់យើងខ្ញុំ អ្នកនឹងត្រូវផ្ដល់លេខកូដចូលប្រើក្រុមហ៊ុន Primark (106502) ហើយបន្ទាប់មក អ្នកអាចសរសេរសារដែលរៀបរាប់លម្អិតអំពីបញ្ហាកង្វល់របស់អ្នក។ អត្ថបទ/អក្សរដែលមាននៅលើសេវាលើវិបសាយគឺជាភាសាក្នុងស្រុករបស់អ្នក។

ក្នុងករណីដែលអ្នកសម្រេចប្រើប្រាស់កម្មវិធីស្មាតហ្វូនប្រាប់យើងខ្ញុំ អ្នកអាចស្កេន QRកូដ ហើយទាញយកកម្មវិធីដោយឥតគិតថ្លៃបាន។ នៅពេលនោះ អ្នកនឹងត្រូវផ្ដល់ ឬវាយបញ្ចូលលេខកូដចូលប្រើក្រុមហ៊ុន Primark (106502) ហើយបន្ទាប់មក អ្នកអាចសរសេរសារដែលរៀបរាប់លម្អិតអំពីបញ្ហាកង្វល់របស់អ្នក។ អត្ថបទ/អក្សរដែលមាននៅលើកម្មវិធីនេះគឺជាភាសាក្នុងស្រុករបស់អ្នក។

លើសពីនេះ ព័ត៌មានលម្អិតនៃលេខទូរសព្ទ អាសយដ្ឋានវិបសាយ លេខកូដចូលប្រើប្រាស់ និងលេខកូដ QR សម្រាប់ប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ(Tell Us) និងមានបិទបង្ហាញឲ្យអ្នកឃើញនៅនៅតាមរោងចក្រដែលផ្គត់ផ្គង់ផលិតផលក្រុមហ៊ុន Primark ផងដែរ។ វាជាក្ដីបារម្ភបំផុតរបស់យើងដែលអ្នកអាចចូលប្រើយន្តការប្រាប់យើងខ្ញុំ(Tell us) បានយ៉ាងងាយស្រួល ហើយមានអារម្មណ៍ស្រួលក្នុងការប្រើប្រាស់វា។ ជាផ្នែកមួយនៃកម្មវិធីត្រួតពិនិត្យសង្គមជាទៀងទាត់នៃរោងចក្រ ក្នុងក្រុមអ្នកផ្គត់ផ្គង់ របស់យើង យើងនឹងពិនិត្យមើលលទ្ធភាពកាបិទនៃផ្ទាំងរូបភាព និងសម្ភារៈព័ត៌មានពាក់ព័ន្ធផ្សេងទៀត ក៏ដូចជាការយល់ដឹងរបស់អ្នកអំពីយន្តការនេះ។

កំណត់ត្រានៃកង្វល់ដែលបានលើកឡើងជាមួយ Primark នឹងត្រូវបានរក្សាទុកដោយអនុលោមតាមច្បាប់ជាធរមាន។ ទាក់ទងទៅនឹងខ្សែទូរស័ព្ទ ប្រាប់យើងខ្ញុំ(Tell Us) ប្រតិចារិកនៃសារសំឡេងរបស់អ្នក ឬការថតសំឡេងត្រូវបានធ្វើឡើង។

ការរាយការណ៍របស់អ្នកនិង ត្រូវដោះស្រាយដោយអនុលោមតាមនីតិវិធី ប្រាប់យើងខ្ញុំ របស់យើង ដែលចែងដូចខាងក្រោម។

## តើនិងមានអ្វីកើតឡើងបន្ទាប់ពីអ្នកទំនាក់ទំនង Primark តាមរយៈការប្រើប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ(Tell Us)?

អ្នកនឹងទទួលបានលេខសំណុំរឿងមួយ។ ក្នុងករណីដែលអ្នកត្រឡប់ទៅប្រើបណ្ដាញទូរសព្ទប្រាប់យើងខ្ញុំ សេវាលើវិបសាយ ឬកម្មវិធីស្មាតហ្វូនវិញ ហើយប្រើលេខនេះ អ្នកអាចនឹងស្ដាប់/អានការទទួលស្គាល់របាយការណ៍របស់អ្នក (ក្រោយរយៈពេល 7 ថ្ងៃ) រាល់សំណើសុំព័ត៌មានបន្ថែម និងធ្វើបច្ចុប្បន្នភាពលើស្ថានភាពនៃការព្រួយបារម្ភរបស់អ្នក។

យើងខ្ញុំមានគោលដៅទទួលស្គាល់របាយការណ៍របស់អ្នកក្នុងរយៈពេលប្រាំពីរថ្ងៃ។ បន្ទាប់មកទៀត យើងខ្ញុំត្រូវធ្វើការវាយតម្លៃជាដំបូងមួយ (ជាផ្នែកមួយនៃដំណើរការនេះ) អ្នកនឹងមានការស្នើសុំឲ្យ ផ្ដល់ព័ត៌មានបន្ថែមអំពីបញ្ហាកង្វល់របស់អ្នក (ដោយផ្អែកលើអ្វីដែលមានការរកឃើញ) នឹងកំណត់ចំណាត់ការណ៍ដែលត្រូវប្រកាន់យក និងពេលវេលាជាប់ពាក់ព័ន្ធ។

អ្នកនឹងទទួលបានព័ត៌មានអំពីលទ្ធផលនៃការស៊ើបអង្កេត និងចំណាត់ការណ៍ទាំងឡាយណាដែលបានគ្រោងទុក ឬមានការប្រកាន់យក និងមូលហេតុចំពោះវិធានការបែបនេះ (ដោយស្ថិតក្រោមលក្ខខណ្ឌរក្សាការសម្ងាត់)។ យើងខ្ញុំសូមធានាថា បុគ្គលដែលទទួលខុសត្រូវចំពោះដំណើរការស៊ើបអង្កេតបណ្ដឹងសាទុក្ខ ឬតវ៉ាតាមប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ គឺជាក្រុមមនុស្សឯករាជ្យ និងមិនលំអៀង។

ក្នុងករណីដែលអ្នកមិនពេញចិត្តចំពោះការឆ្លើយតបដែលអ្នកទទួលបាននៅត្រង់ចំណុចណាមួយនោះ សូមចាំថា អ្នកអាចទៅកាន់ទំនាក់ទំនងណាមួយផ្សេងទៀតដែលរៀបរាប់លម្អិតនៅក្នុងគោលការណ៍ប្រាប់យើងខ្ញុំ ដែលបានកំណត់ខាងដើមបាន។ យើងខ្ញុំមានការប្ដេជ្ញាចិត្តចំពោះការធានាឲ្យបានថា បញ្ហាទាំងនេះគឺពិតជាមានការដោះស្រាយបានប្រកបដោយយុត្តិធម៌ និងត្រឹមត្រូវ។

## តើអ្នកត្រូវបានការពារតាមរបៀបណា ក្នុងករណីដែលអ្នកទាក់ទងមកក្រុមហ៊ុន Primark តាមរយៈការប្រើប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ?

### ពីផលប៉ះពាល់

យើងនឹងមិនអត់ឱនចំពោះការសងសឹកប្រឆាំងនឹងនរណាម្នាក់ដែលលើកឡើងពីការព្រួយបារម្ភនោះទេះ បុគ្គលណាម្នាក់ដែលលើកឡើងពីការព្រួយបារម្ភគួរតែត្រូវបានការពារពីផលប៉ះពាល់ អវិជ្ជមាន ការសងសឹក ឬការខូចខាត។ បើអ្នកមានអារម្មណ៍គិតឃើញថា មានផលប៉ះពាល់អាក្រក់ណាមួយចំពោះរូបអ្នក ឬការងារអ្នកដែលបណ្ដាលមកពីការលើកយកបញ្ហាកង្វល់មកនិយាយ ឬ ដោះស្រាយនោះ ត្រូវរាយការណ៍អំពីបញ្ហានេះជាបន្ទាន់តាមរយៈការប្រើបណ្ដាញទូរសព្ទ សេវាលើវិបសាយ ឬកម្មវិធីប្រាប់យើងខ្ញុំ ។

## អត្តសញ្ញាណ និងសិទ្ធិឯកជនរបស់អ្នក

យើងសង្ឃឹមថា អ្នកនឹងមានអារម្មណ៍ថាអាចនឹងនិយាយប្រាប់មកកាន់យើងខ្ញុំដោយចំហបាន។ ក្នុងករណីដែលអ្នកចង់ធ្វើឲ្យមានលក្ខណៈបែបអនាមិកទាំងស្រុង ដែលអាស្រ័យទៅលើអ្នក ហើយអ្នកអាចធ្វើទៅបានតាមរយៈការប្រើបណ្តាញទូរសព្ទ សេវាលើវិបសាយ ឬកម្មវិធីស្មាតហ្វូនប្រាប់យើងខ្ញុំ ។ សូមនិយាយប្រាប់តែព័ត៌មានទាំងឡាយណាដែលអ្នកគិតថា នឹងជួយឲ្យយើងខ្ញុំអាចដោះស្រាយបញ្ហារបស់អ្នកបាន។ សូមកុំបារម្ភបើអ្នកបានភ្លេចរឿងអ្វីមួយ ពីព្រោះអ្នកមានជម្រើសទាក់ទងមកយើងខ្ញុំបានទៀត បើមិនដូច្នោះទេ អ្នកអាចស្នើសុំឲ្យយើងខ្ញុំទាក់ទងអ្នកដោយផ្ទាល់ ដើម្បីពិភាក្សាគ្នាអំពីបញ្ហារបស់អ្នកបាន។

បើអ្នកពិតជាបើកចំហអត្តសញ្ញាណរបស់អ្នក យើងនឹងចាត់វិធានការសមស្របទាំងអស់ដើម្បីរក្សាអត្តសញ្ញាណរបស់អ្នកជាឯកជននិងសម្ងាត់។ យើងនឹងប្រើឈ្មោះរបស់អ្នកចំពោះអ្នកដែលត្រូវដឹងដើម្បីស៊ើបអង្កេតការចោទប្រកាន់ ឬបើមិនដូច្នេះទេតាមច្បាប់។ ព័ត៌មានផ្ទាល់ខ្លួនទាំងឡាយណាដែលកំណត់អត្តសញ្ញាណអ្នកឬបុគ្គលផ្សេងទៀតដែលទទួលបានជាផ្នែកមួយនៃបញ្ហាកង្វល់ណាមួយដែលបានលើកយកមកនិយាយក្រោមលក្ខខណ្ឌនៃគោលការណ៍ស្តីពីការប្រាប់យើងខ្ញុំនេះ នឹងមានការប្រើសម្រាប់គោលបំណងដែលមានការបរិយាយនៅក្នុងគោលការណ៍ស្តីពីការប្រាប់យើងខ្ញុំនេះ និងយោងតាមសេចក្តីជូនដំណឹងអំពីសិទ្ធិឯកជនដែលមាននៅក្នុងឧបសម្ព័ន្ធទី 2 ប៉ុណ្ណោះ។

ដោយមិនគិតចំពោះលក្ខខណ្ឌដែលអ្នកត្រូវសម្រេចជ្រើសយកបែបអនាមិក ឬការមិនបញ្ចេញឈ្មោះនោះ យើងខ្ញុំមិនដែលបញ្ចូលព័ត៌មានអំពីកម្មករនិយោជិតនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់យើងខ្ញុំទៅក្នុងរបាយការណ៍ដែលយើងខ្ញុំបានបោះពុម្ពផ្សាយស្តីពីបណ្តឹងតវ៉ាដែលនឹងនាំទៅដល់ការកំណត់អត្តសញ្ញាណរបស់ពួកគេបាននោះទេ។

## ផ្សេងៗទៀត

ក្នុងករណីដែលមិនមានការចែងផ្សេងពីនេះដោយច្បាប់ គោលការណ៍ស្តីពីការប្រាប់យើងខ្ញុំនេះ នឹងមិនជាផ្នែកមួយនៃកិច្ចសន្យាការងាររបស់អ្នកទេ ហើយក៏មិនផ្តល់ជាមូលដ្ឋានសម្រាប់កិច្ចសន្យាបែបនេះជាមួយនឹងក្រុមហ៊ុន Primark ដែរ គឺយើងខ្ញុំអាចនឹងកែប្រែគោលការណ៍ស្តីពីការប្រាប់យើងខ្ញុំ បានគ្រប់ពេល។

## ឧបសម្ព័ន្ធទី 1

## ប្រព័ន្ធទូរសព្ទស្នើសុំជំនួយរបស់កម្មករនិយោជិតនៅមូលដ្ឋាន ឬនៅក្នុងប្រទេស

| ឈ្មោះ | ប្រទេស | ទូរសព្ទ និង/ឬវិបសាយ |
|---|---|---|
| អាម៉ាដេកូថា | បង់ក្លាដេស | 08006666666 |
| ផ្នែកជំនួយកម្មករនិយោជិត MUDEM | ទួរគី | https://iscidestekmerkezi.org |
| ក្រុមប្រឹក្សាការពារនិរន្តរភាព (RSC) របស់ RMG | បង់ក្លាដេស | បណ្តឹងអំពីបញ្ហាសុវត្ថិភាព:<br>08801769969000<br><br>សំណួរជាទូទៅ:<br>08801766695900<br>0880241081863-6 |
| អ៊ិនហ្គាល់គួរ៉ាល់ | ឥណ្ឌា | 1-800-8333-12 |

| | | |
|---|---|---|
| UNGAL KURAL உங்கள் குரல் | | |

## ឧបសម្ព័ន្ធទី 2

## ប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ – សិទ្ធិឯកជនរបស់អ្នក

សម្រាប់គោលបំណងនៃច្បាប់ការពារទិន្នន័យអឺរ៉ុប ក្រុមហ៊ុន Primark គឺជាអ្នកគ្រប់គ្រងទិន្នន័យដែលមានទំនួលខុសត្រូវលើព័ត៌មានផ្ទាល់ខ្លួនដែលអ្នកបញ្ជូនតាមរយៈបណ្តាញទូរសព្ទ សេវាលើវិបសាយ និងកម្មវិធីស្មាតហ្វូនប្រាប់យើងខ្ញុំ ។

## ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក

យើងខ្ញុំប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនដែលបានបញ្ជូនក្រោមលក្ខខណ្ឌនៃគោលការណ៍ស្តីពីការប្រាប់យើងខ្ញុំ សម្រាប់គោលបំណងនៃការស៊ើបអង្កេតលើការចោទប្រកាន់អំពីបញ្ហាអាកប្បកិរិយាមិនត្រឹមត្រូវ មិនសមរម្យ មិនស្មោះត្រង់ ខុសច្បាប់ ឬអាកប្បកិរិយាគ្រោះថ្នាក់ ("អាកប្បកិរិយាមិនសមរម្យ") នៅក្រោមលក្ខខណ្ឌនៃគោលការណ៍ស្តីពីការប្រាប់យើងខ្ញុំ និងអនុលោមតាមច្បាប់ពាក់ព័ន្ធ។
ការជូនដំណឹងនេះប្រាប់អ្នកអំពីព័ត៌មានដែលយើងប្រមូលនៅពេលអ្នករាយការណ៍អំពីអាកប្បកិរិយាមិនសមរម្យ និងរបៀបដែលព័ត៌មាននោះត្រូវបានប្រើប្រាស់ និងចែករំលែកនៅក្នុង Primark ។

## តើយើងដំណើរការទិន្នន័យផ្ទាល់ខ្លួនអ្វីខ្លះ?

ក្នុងករណីដែលអ្នករាយការណ៍អំពីបញ្ហាមួយតាមរយៈបណ្តាញទូរសព្ទ សេវាលើវិបសាយ ឬកម្មវិធីស្មាតហ្វូនប្រាប់យើងខ្ញុំ យើងខ្ញុំ ប្រមូលព័ត៌មានលម្អិតផ្ទាល់ខ្លួនដែលអ្នកបញ្ចូលនៅក្នុងរបាយការណ៍របស់អ្នកអំពីអ្នក ឬមនុស្សណាម្នាក់ដែលអ្នកបានកំណត់អត្តសញ្ញាណនៅក្នុងរបាយការណ៍របស់អ្នក។ យើងខ្ញុំមិនទាមទារឲ្យអ្នកប្រាប់ឈ្មោះទេ។ យើងខ្ញុំសូមលើកទឹកចិត្តឲ្យអ្នកកំណត់អត្តសញ្ញាណអ្នកខ្លួនឯង ពីព្រោះបញ្ហាកង្វល់ដែលលើកយកមកនិយាយបែបអនាមិកមិនសូវជាមានប្រសិទ្ធភាពទេ ហើយក្នុងករណីដែលយើងមិនទទួលបានព័ត៌មានគ្រប់គ្រាន់ ដំណើរការស៊ើបអង្កេតពេញលេញប្រហែលជា មិនអាចធ្វើទៅរួចនោះទេ។

អ្នកអាចនឹងដាក់បញ្ចូលព័ត៌មានផ្ទាល់ខ្លួនទៅក្នុងចំណាត់ថ្នាក់ពិសេសៗដែលជួនកាលត្រូវបានគេហៅថាៈ“ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់”។ ពាក្យនេះមានជាអាទិ៍ ព័ត៌មានទាក់ទងនឹងបញ្ហាដូចជា ជាតិសាសន៍ ឬជនជាតិភាគតិច ជំនឿសាសនា សុខភាពផ្លូវកាយ ឬផ្លូវចិត្ត សមាជិកភាពសហជីព ទំនោរផ្លូវភេទ ព័ត៌មានទាក់ទងនឹងជីវិតផ្លូវភេទ ព័ត៌មានជីវមាត្រ ទិន្នន័យហ្សែន ព្រឹត្តិបត្រថ្កោលទោស និងព័ត៌មានទាក់ទងបទល្មើស ឬការជម្រះរឿងក្តីព្រហ្មទណ្ឌ។

ក្នុងករណីដែលអ្នកជាកម្មវត្ថុនៃរបាយការណ៍ ឬមានឈ្មោះក្នុងរបាយការណ៍ យើងខ្ញុំនឹងព្យាយាមជូនដំណឹងដល់អ្នកភ្លាមៗ លុះត្រាតែការធ្វើដូច្នេះអាចប៉ះពាល់ដល់ការស៊ើបអង្កេត ឬយើងត្រូវបានហាមឃាត់មិនឱ្យធ្វើដូច្នេះដោយច្បាប់។

## តើយើងខ្ញុំប្រើទិន្នន័យនេះ យ៉ាងដូចម្តេច?

របាយការណ៍ជាសំឡេង ដែលបានបញ្ជូនតាមរយៈបណ្តាញទូរសព្ទប្រាប់យើងខ្ញុំ(Tell Us) មានការរក្សាទុកយ៉ាងសង្ខេប ហើយបន្ទាប់មកប្រតិចារិក(បកប្រែជាអក្សរ) ដែលបង្កើតឲ្យមានឡើងទាំងជាភាសាដើម និងទាំងភាសាអង់គ្លេស។ រាល់ប្រតិចារឹក និងរបាយការណ៍ទាំងអស់ដែលទទួលបានមកតាមរយៈសេវាលើវិបសាយ និងកម្មវិធីស្មាតហ្វូនប្រាប់យើខ្ញុំ ដោយមិនគិតពីប្រទេសដើម មានការរក្សាទុកក្នុងប្រព័ន្ធគ្រប់គ្រងសំណុំរឿង និង បញ្ជូនទៅកាន់ក្រុមហ៊ុន Primark។

យើងខ្ញុំប្រើប្រាស់ទិន្នន័យដែលមានការបញ្ជូនមកឲ្យយើងខ្ញុំសម្រាប់គោលបំណងពិនិត្យមើលរបាយការណ៍ ហើយ (ក្នុងករណីសមស្រប) ធ្វើការស៊ើបអង្កេតលើការចោទប្រកាន់ដែលបានធ្វើឡើង។ ការប្រើប្រាស់ទិន្នន័យរបស់យើងខ្ញុំនេះ ជាទូទៅគឺសំខាន់ចាំបាច់សម្រាប់ផលប្រយោជន៍ស្របច្បាប់របស់យើងខ្ញុំដែលទាក់ទងនឹងគោលបំណងទាំងនេះ ហើយយើងខ្ញុំបានដាក់ចេញនូវវិធានការណ៍សមស្របនានាដែលនឹងការពារបុគ្គលដែលចូលរួមពាក់ព័ន្ធបាន។

ក្នុងករណីដែលរបាយការណ៍របស់អ្នកបូកបញ្ចូលប្រភេទទិន្នន័យផ្ទាល់ខ្លួនពិសេសៗ និង/ឬ ទិន្នន័យផ្ទាល់ខ្លួនទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ ឬដំណើរការនិតិវិធី និយាយជាទូទៅយើងប្រប្រាស់ទិន្នន័យគឺចាំបាច់សម្រាប់ផលប្រយោជន៍ស្របច្បាប់របស់យើង (ដូចដែលបានបរិយាយខាងដើម) និង:

- ទាក់ទងនឹងការប្រើប្រាស់ប្រភេទពិសេសនៃទិន្នន័យផ្ទាល់ខ្លួន ដែលចាំបាច់សម្រាប់ផលប្រយោជន៍សាធារណៈយ៉ាងច្រើន និង/ឬចាំបាច់សម្រាប់ការបង្កើត ឬការពារការទាមទារផ្នែកច្បាប់ និង
- ដោយយោងទៅលើព័ត៌មានទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ ឬការចោទប្រកាន់ ចាំបាច់ត្រូវអង្កេតរកឲ្យឃើញ ឬទប់ស្កាត់អំពើខុសច្បាប់។

## ការចែករំលែកទិន្នន័យរបស់អ្នក

របាយការណ៍ទាំងឡាយណាដែលមានការបញ្ជូនតាមរយៈប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ(Tell us) ដែលពាក់ព័ន្ធនឹងបញ្ហាក្រមសីលធម៌ នឹងមានការបញ្ជូនទៅឲ្យក្រុមការងារជំនួញក្រមសីលធម៌ (ET)របស់ក្រុមហ៊ុន Primark ដើម្បីដោះស្រាយបញ្ហាតាមនីតិវិធីដែលមានចែងក្នុងគោលការណ៍ស្តីពីការប្រាប់យើងខ្ញុំ ។

តាមធម្មតា របាយការណ៍ផ្សេងៗទៀតត្រូវមានការបញ្ជូនទៅកាន់ក្រុមការងារជាប់ពាក់ព័ន្ធនៅក្រុមហ៊ុន Primark ដើម្បីជួយដល់ការ ស៊ើបអង្កេតសមស្រប។

ដើម្បីរក្សាបាននូវទិដ្ឋភាពទូទៅនៃនិន្នាការ ឬផ្នែកណាមួយនៃបញ្ហាកង្វល់ (ក្នុងករណីដែលចាំបាច់ត្រូវមានការបណ្តុះបណ្តាលបន្ថែម ឬវិធានការណ៍ផ្សេងៗទៀត) របាយការណ៍ទាំងអស់ត្រូវមានការធ្វើឲ្យមានភាពអនាមិក និងផ្ទៀងផ្ទាត់ដាក់បញ្ចូលទៅក្នុងរបាយការណ៍សង្ខេបដោយក្រុមហ៊ុន Primark សម្រាប់ការត្រួតពិនិត្យប្រចាំត្រីមាសដោយនាយកក្រុមហ៊ុន Primark ផ្នែកបញ្ហាហានិភ័យ និងការអនុលោមតាមច្បាប់។

## តើយើងខ្ញុំត្រូវរក្សាទុកទិន្នន័យរបស់អ្នករយៈពេលប៉ុណ្ណា?

ការថតសំឡេងលើកដំបូងនឹងមានការលុបចោលនៅពេលដែលប្រតិចារិក(បកប្រែជាអ្នក)មានការបង្កើតឡើង។ ប្រតិចារិកនៃរបាយការណ៍ និងរបាយការណ៍ដែលទទួលបានតាមរយៈ វិបសាយ និងកម្មវិធីស្មាតហ្វូនប្រាប់យើងខ្ញុំ នឹងមានការរក្សាទុកនៅក្នុងប្រព័ន្ធកម្មវិធីប្រាប់យើងខ្ញុំ នៅរយៈពេលនៃការស៊ើបអង្កេត និងនៅពេលដែលសំណុំរឿងមាន 'ការបិទបញ្ចប់ហើយ' នៅរយៈពេលបីឆ្នាំបន្ថែមទៀត (លុះត្រាតែត្រូវការរយៈពេលវែងជាងនេះ ក្រោមការអនុវត្តន៍ច្បាប់)។ នៅពេលនោះ រាល់ទិន្នន័យកំណត់អត្តសញ្ញាណទាំងអស់ ត្រូវបានការលុបចោល ហើយមានតែកំណត់ត្រាស្ថិតិប្រភេទរបាយការណ៍ ទីកន្លែង និងលទ្ធផលចុងក្រោយនៃដំណើរការស៊ើបអង្កេតប៉ុណ្ណោះដែលមានការរក្សាទុកសម្រាប់គោលបំណងរាយការណ៍ផ្ទៃក្នុង។

## តើទិន្នន័យរបស់អ្នករក្សាទុកនៅឯណា និងការផ្ទេរទៅណា?

របាយការណ៍ដែលបានបញ្ជូនតាមរយៈបណ្តាញទូរសព្ទ សេវាលើវិបសាយ និងកម្មវិធីស្មាតហ្វូនប្រាប់យើងខ្ញុំ នឹងមានការរក្សាទុកនៅលើម៉ាស៊ីនមេនៃអ្នកផ្គត់ផ្គង់របស់យើងខ្ញុំនៅប្រទេសហូឡង់ (អឺរ៉ុប)។ លើសពីនេះ ទិន្នន័យរបស់អ្នកនឹងមានការចូលប្រើដោយក្រុមហ៊ុន Primark នៅចក្រភពអង់គ្លេស និងអៀរឡង់ ហើយបន្ទាប់មក មានការបែងចែកការស៊ើបអង្កេតលើអាជីវកម្មដែលសមស្របបំផុត។ នេះមានន័យថា ទិន្នន័យរបស់អ្នកនឹងមានការផ្ទេរទៅកាន់ចក្រភពអង់គ្លេស ប្រទេសអៀរឡង់ និងហូឡង់ និងទៅកាន់ក្រុមការងារស៊ើបអង្កេតដែលជាប់ពាក់ព័ន្ធ នៅគ្រប់ទីកន្លែងដែលពួកគេឈរជើង។

## សិទ្ធិរបស់អ្នក

អ្នកអាចស្នើសុំឲ្យយើងខ្ញុំផ្តល់ឲ្យអ្នកនូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក មួយច្បាប់បានគ្រប់ពេល។ ក្នុងករណីដែលអ្នកគិតថា ទិន្នន័យផ្ទាល់ខ្លួនដែលយើងខ្ញុំរក្សាទុក មិនត្រឹមត្រូវ ឬមិនពេញលេញ អ្នកអាចនឹងស្នើសុំឲ្យយើងកែតម្រូវ ឬបំពេញវាបាន។ ស្ថិតក្នុងករណីមួយចំនួន អ្នកក៏មានសិទ្ធិជំទាស់ចំពោះការប្រើប្រាស់ព័ត៌មានរបស់អ្នក និងសិទ្ធិស្នើសុំឲ្យយើងខ្ញុំដាក់កម្រិតលក្ខខណ្ឌលើការប្រើប្រាស់ព័ត៌មានរបស់អ្នក ឬលុបវាចោលបាន។ ទោះបីជាយ៉ាងណាក៏ដោយក៏នៅមានករណីលើកលែងមួយចំនួនចំពោះសិទ្ធិទាំងនេះដែរ។ ឧទាហរណ៍: វានឹងមិនអាចឲ្យយើងយើងលុបចោលទិន្នន័យរបស់អ្នកបានទេ បើច្បាប់តម្រូវអោយរក្សាទុក ឬបើយើងខ្ញុំត្រូវការប្រើវាដើម្បីបង្កើតឲ្យមាន ឬការពារការទាមទារផ្នែកច្បាប់។

ក្នុងករណីដែលអ្នកចង់ចូលប្រើទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ឬអនុវត្តសិទ្ធិណាមួយរបស់អ្នក អ្នកត្រូវទាក់ទងទៅក្រុមការងារការពារទិន្នន័យរបស់ក្រុមហ៊ុន Primark តាមអ៊ីម៉ែល ទៅកាន់អាសយដ្ឋាន dataprotection@primark.ie ជាមុនសិន។ ក្នុងករណីដែលអ្នកមានបញ្ហាកង្វល់អំពីរបៀបដែលយើងខ្ញុំកាន់កាប់ និងដោះស្រាយបញ្ហាទិន្នន័យរបស់អ្នក អ្នកមានសិទ្ធិប្តឹងតវ៉ាទៅអាជ្ញាធរត្រួតពិនិត្យការការពារទិន្នន័យនៅប្រទេសរបស់អ្នកបាន។